# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យ**

**ការងារអធិការកិច្ចហត្ថពលកម្មបរទេស**

លេខៈ ០០១/ ក.ស.រ /២២

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាន
## គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធាន
## គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/រកម/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ៨៩ សសរ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស
- យោងសំណូមពរចាំបាច់នៃការងារ

## **សម្រេច**

**ប្រការ ១.**_

ត្រូវបានបង្កើតលេខាធិការដ្ឋានធ្វើជាសេនាធិការជូនគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស មានទីតាំងស្ថិតនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **នៅ លក្ខណា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** | អគ្គនាយកអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តម **សេខ សក្តា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុវណ្ណា ពិសាខា** | អគ្គនាយករងអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯកឧត្តម **សួន សទ្ធាវុទ្ធី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦. លោក **ជួប ណារ៉ាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៧. លោក ឧត្តមសេនីយ៍ឯក **ម៉ៅ ពៅ** | អនុប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. លោក ឧត្តមសេនីយ៍ឯក **សៀន សេន** | ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩. លោក ឧត្តមសេនីយ៍ទោ **ហាស់ សុត្ថា** | ប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ ក្រសួងមហាផ្ទៃ | សមាជិក |
| ១០. លោក ឧត្តមសេនីយ៍ទោ **អ៊ឹង ចាន់តារ៉ា** | អនុប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១. លោក ឧត្តមសេនីយ៍ទោ **គង់ ណារិទ្ធ** | អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ | សមាជិក |

១២. លោក **ហេង ហ៊ត** អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៣. លោក **ស៊ឹម ហុង** អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៤. លោក **ជួន អានសទ្វារ** អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៥. លោក **ម៉ៅ សុចា** ប្រធានការិយាល័យនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

**ប្រការ ២.**_

លេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

-កសាងផែនការសកម្មភាព គោលការណ៍ណែនាំ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ការងាររបស់គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស

-សម្របសម្រួលការងាររដ្ឋបាល និងបច្ចេកទេសជាមួយលេខាធិការដ្ឋាននៃគណៈបញ្ជាការដឹកនាំប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ រដ្ឋបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ

-រៀបចំលិខិតអញ្ជើញ បន្ទប់ប្រជុំ ពិធីការ និងធ្វើកំណត់ហេតុសម្រាប់គ្រប់កិច្ចប្រជុំនានារបស់គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស

-ធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេសតាមកាលកំណត់ជូនសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល

-រៀបចំផែនការថវិកាហិរញ្ញវត្ថុដាក់ជូនប្រធានគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ពិនិត្យ និងសម្រេច

-អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស។

**ប្រការ ៣.**_

-ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន មានសិទ្ធិចាត់ចែងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមតម្រូវការចាំបាច់នៃការងារ

-អនុប្រធាន សមាជិកលេខាធិការដ្ឋានចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៤.**_

រាល់លិខិតស្នាមជាផ្លូវការរបស់គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ៚

**ប្រការ ៥.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.**_

គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស គណៈបញ្ជាការដឹកនាំប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រុមការងារបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ រដ្ឋបាលរាជធានី ខេត្ត សមត្ថកិច្ចពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិ ឆ្នាំ២០២២

**រដ្ឋមន្ត្រី និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យ**

**ការងារអធិការកិច្ចហត្ថពលកម្មបរទេស**

**អ៊ិត សំហេង**

កន្លែងទទួល៖

-ក្រសួងមហាផ្ទៃ

-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

-ក្រសួងយុត្តិធម៌

-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យសម្ដេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៦

-ឯកសារ-កាលប្បវត្តិ